**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**

**<u>ហ្សាការតា</u>**

*លេខ : 77/REC-JKT/010* *ហ្សាការតា ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១០*

**សូមជូនចំពោះ**

**លោកប្រធាននាយកដ្ឋានអាស៊ី ១**

***<u>កម្មវត្ថុ</u>*** *: អំពីការផ្តល់ Visa-on-arrival ដល់ពលរដ្ឋខ្មែរចូលសាធារណរដ្ឋឥណ្ឌូនេស៊ី*

***<u>យោង</u>*** *: លិខិត ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ របស់នាយកដ្ឋានអាស៊ី ១ ។*

*ខ្ញុំមានកិត្តិយសសូមជំរាបជូន **លោកប្រធាន នាយកដ្ឋានអាស៊ី ១** ជ្រាបថា តាម New regulation No. M.HH-01.GR.01.06.Year 2010 របស់ក្រសួងយុត្តិធម៌និងសិទ្ធិមនុស្សឥណ្ឌូនេស៊ីស្តីពី Visa-on-arrival ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ “ប្រជាពលរដ្ឋរបស់ប្រទេសមានក្នុងបញ្ជីដូចជូនភ្ជាប់ ដែលកាន់លិខិតឆ្លងដែនប្រភេទធម្មតា ក្នុងនោះក៏មានប្រទេសកម្ពុជាយើង នៅពេលធ្វើទស្សនកិច្ចនៅឥណ្ឌូនេស៊ីជាអ្នកទេសចរណ៍. ជាការមកលេងគ្រួសារ. ការធ្វើពាណិជ្ជកម្ម និងការមកធ្វើទស្សនកិច្ចផ្ទាល់របស់មន្រ្តីរដ្ឋាភិបាល (យោងតាមប្រការ២) អាចទទួលបាន Visa-on-arrival សំរាប់ស្នាក់នៅសាធារណរដ្ឋឥណ្ឌូនេស៊ីរយៈពេល ០១ ខែ និងអាចពន្យាពេលបាន ៣០ ថ្ងៃ បន្តទៀត នៅនាយកដ្ឋានអន្តោប្រវេសន៍ឥណ្ឌូនេស៊ី ” ដូចមាន New regulation នេះជូនភ្ជាប់មកជាមួយ ។*

*សូម **លោកប្រធាន** ជ្រាប និងទទួលនៅការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។*

***ឯកអគ្គរាជទូត***

***កាន់ ផារិទ្ធ***